ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...សហវ...

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០១០

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** ករណីសំណើសុំថវិកាចំនួន ៣.៦៣០.៩៧៨,៧៣ ដុល្លារអាមេរិក សម្រាប់ការងារជួសជុល និងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រកំពង់រាំង (ប្រព័ន្ធធារាសាស្ត្របឹងមេសរ) ។

**យោង:** លិខិតលេខ១៣៤៩ ធទឧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមឯកឧត្តមមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមឯកភាពជាគោលការណ៍ផ្តល់នូវថវិកាចំនួន ៣.៦០០.០០០ ដុល្លារអាមេរិក (បីលានប្រាំមួយរយពាន់ដុល្លារអាមេរិក) ជូនក្រសួងធនធានទឹក និងឧតុនិយម សម្រាប់ជួសជុល និងស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រកំពង់រាំង ស្ថិតក្នុងស្រុកឆ្លូង ខេត្តក្រចេះ ដោយប្រើប្រាស់ថវិកាក្រោមហិរញ្ញប្បទានសហប្រតិបត្តិការរបស់ ADB លេខ 2480-CAM (SF) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន តាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-សាលាខេត្តក្រចេះ
-មន្ទីរធនធានទឹក និងឧតុនិយមខេត្តក្រចេះ
-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តក្រចេះ
-ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798